# ខ្លឹមសារសង្ខេប

## សេចក្តីសម្រេចលើសំណើរបស់ភាគីនានាសុំដាក់សម្ភារៈ មួយចំនួននៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(២) http://www.measboralaws.com/detail/1055

១. ក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡ ការស៊ើបអង្កេត ជាចម្បងពិសេសក្នុងសំណុំរឿងបទឧក្រិដ្ឋ ត្រូវបានធ្វើឡើងដោយចៅក្រមស៊ើបសួរ (investigating judge: IJ) បង្កើតបានជាឯកសារសំណុំរឿង (case file: CF) ដែលនឹងត្រូវបានដាក់ដេញដោយរវាងភាគីក្នុងអំឡុងពេលសវនាការ។ បន្ថែមពីលើនេះ ភាគីអាចស្នើដាក់ឯកសារថ្មីបន្ថែមក្នុងអំឡុងពេលនោះ។

២. ក្នុងដំណើរការសវនាការ នៃសំណុំរឿង ០០១ របស់ អវតក ភាគីបានស្នើដាក់បន្ថែមឯកសារមួយចំនួន។[1]វិធានទី ៨៧ នៃវិធានផ្ទៃក្នុង អវតក http://www.measboralaws.com/detail/1054 ចែងថា អង្គជំនុំជម្រះ (Trial Chamber:TC) សម្រេចសេចក្តី ផ្អែកលើភស្តុតាង (evidence) ដាក់ចំពោះមុខ និងដាក់ក្រោមការពិចារណា (subjected to examination)។ ឯកសារទាំងនោះ ត្រូវបានពិចារណាថាបានដាក់ប្រសិនបើខ្លឹមសារ ត្រូវបានសង្ខេប អានក្នុងតុលាការ ឬ ត្រូវបានកំណត់ត្រឹមត្រូវ (appropriately identified)។ ការដាក់ក្រោមការពិចារណា ជាការដាក់ឲ្យភាគី ដេញដោល (adversarial argument) (កថា. ២)។ អត្ថបទស្រាវជ្រាវ ឬសាលក្រម យោងសម្រាប់គាំទ្រអំណះអំណាងផ្លូវច្បាប់ (legal submission) មិនត្រូវបានចាត់ជាភស្តុតាងទេ។ លិខិតរបស់ព្រះមហាក្សត្រ ត្រូវបានចាត់ថាជាភស្តុតាង (កថាទី១៣)។ បន្ថែមពីលើនេះ ឯកសារបង្កើតជាភស្តុតាង ទទួលបានដោយទារុណកម្ម នឹងមិនត្រូវបានទទួលយកទេ ដោយសារភាពមន្ទិលលើខ្លឹមសារពិតប្រាកដ នៃឯកសារ(កថាទី៨) http://www.measboralaws.com/detail/1057។

៣. ភាគីអាចស្នើដាក់នូវឯកសារទាំងមូល ឬដោយផ្នែក ហើយតុលាការទុកឱកាសឲ្យភាគីដទៃទៀត ធ្វើការកត់សំគាល់ឆ្លើយតប។ ភាគីមានសិទ្ធិជំទាស់។ អ្វីសំខាន់គឺការសម្រេច របស់ TC ថាតើភស្តុតាងនោះ វាពាក់ព័ន្ធ និង គួរឲ្យទុកចិត្តបាន។ *ដើម្បីបង្កើតបានជាភស្តុតាង សម្ភារៈត្រូវបំពេញឲ្យបាននូវបទដ្ឋានអប្បបរមា ដូចជាភាពជាប់ពាក់ព័ន្ធ និងភាគអាចជឿជាក់បាន*។[2] ផ្អែកលើមូលដ្ឋានទាំងនេះ TC បានបដិសេធ មិនទទួលយកឯកសារខ្លះ ដោយសារមិនពាក់ព័ន្ធ ច្រំដែល ឬមិនត្រូវបានកំណត់ត្រឹមត្រូវ (កថា. ៦)។ បន្ថែមពីលើនេះ ឯកសារខ្លះ មិនជួយស្វែងរកការពិត (not conductive to ascertaining the

---

[1] ឯកសារឧបសម្ព័ន្ធ ស្នើដោយសហព្រះរាជអាជ្ញា សំណុំរឿង ០០១, D99/1។ ឯកសារស្នើដោយ ជនជាប់ចោទ http://www.measboralaws.com/detail/1058។

[2] Material should satisfy minimum standards such as relevant and reliability, para. 3.

truth) កថា ទី១៥ ។ ជាចុងក្រោយ ឯកសារមួយចំនួន ដែលដាក់មកនៅមិនទាន់ត្រូវបានពិនិត្យដោយភាគីទេ ដូចនេះ ជនជាប់ចោទ អាចដាក់ការកត់សំគាល់តបបាន (កថាទី ១៦)។

៤. សម្រាប់ឯកសារថ្មី ដែលបង្ហាញអង្គហេតុថ្មី មិនត្រូវបានទទួលទេ ដោយសារ ភាគីធ្វេសប្រហែសដាក់យឺត។ម្យ៉ាងទៀត ប្រសិនបើទទួល ភស្តុតាងពាក់ព័ន្ធ នឹងមិនអាចត្រូវបានបង្កើត ឬប្រមូលបានក្នុងពេលវេលាសមស្របទេ (កថាទី ១៤)។

__**កំណត់សំគាល់**__៖ __១.__ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ៣២១ ចែងថា ភស្តុតាង អាចជូនដល់តុលាការដោយសេរី ហើយចៅក្រមវាយតម្លៃ ដោយផ្អែកលើជំនឿស្មោះត្រង់របស់ខ្លួន។ ចម្លើយសារភាព ក៏ទទួលមកពិនិត្យដែរ។ ក៏ប៉ុន្តែប្រសិនបើរកឃើញថា ទទួលបានក្រោមការបង្ខិតបង្ខំខាងផ្លូវចិត្តក្តី..វាគ្មានតម្លៃជាភស្តុតាងទេ។ ការឆ្លងឆ្លើយរវាងមេធាវី និង ជនជាប់ចោទ មិនមែនជាភស្តុតាងទេ។ តុលាការ សំអាងលើតែភស្តុតាង ដាក់បង្ហាញនៅពេលសវនាការតែប៉ុណ្ណោះ នៅក្នុងសេចក្តីសម្រេច។ មាត្រា ៣៣៤ នៃក្រមដដែល៖ ភាគី អាចជូនលិខិតស្នាម ទាំងអស់ដែលខ្លួនឃើញថាមានប្រយោជន៍ដល់ការសំដែងឲ្យឃើញការពិត រហូតដល់បិទកិច្ចពិភាក្សាដេញដោល (សូមមើលមាត្រា ៣៣៧ បន្ថែម) ។ __២.__ ខ្លឹមសារសេចក្តីសម្រេច បានបង្ហាញពីការលើកកម្ពស់ នូវគោលការណ៍សមភាពរវាងភាគី (equality of arms) ក្នុងកថាខ័ណ្ឌទី ១៦ ដែលបើកឱកាសស្មើភាពដល់ភាគីក្នុងការពិនិត្យមើលភស្តុតាងដាក់បន្ទុក ឬដោះបន្ទុក។ __៣__. សម្រាប់ឯកសារ ដូចជាសៀវភៅ ឬសាលក្រម TC ហាក់មិនចាំបាច់ជូនភាគីលើកយោបល់ទេ (បើមិនចាំបាច់) ដោយសារវាជាឯកសារសាធារណៈ។ នេះទំនង អនុលោមតាមគោលការណ៍ Judicial Notice ដែលអនុវត្តទូលំទូលាយក្នុងប្រព័ន្ធច្បាប់កំមុនឡ សំដៅលើអង្គហេតុទូទៅ គេដឹងលឺ ឬអង្គហេតុក្នុងសំណុំរឿងមុន ដែលភាគីទាំងអស់នៃសំណុំរឿងបានដឹង និងមិនចាំបាច់ដេញដោល ពីភាពពិតប្រាកដទៀតទេ។ នេះជួយឲ្យដំណើរការសវនាការ ប្រព្រឹត្តិទៅបានលឿន កាត់បន្ថយនូវការបំពាន សិទ្ធិទទួលបានសវនាការក្នុងរយៈពេលសមស្រប (right to trial within reasonable time)។ ក្នុងសំណុំរឿង ០០១ នេះ ជនជាប់ចោទ និង សហព្រះរាជអាជ្ញា ក៏បានពិចារណាអំពី Agreed Facts http://www.measboralaws.com/detail/1059 ។ __៤.__ ពាក់ព័ន្ធឯកសារថ្មី (កថា ១៤) TC មិនទទួល ដោយសារភាគីដាក់យឺត។ យុត្តិសាស្ត្រអន្តរជាតិ ប្រើពាក្យ “Fresh Evidence” ដែលអាចទទួលយកបាន លុះត្រាក្នុងករណីចាំបាច់ និងមិនទាំឲ្យមានដំណើររាំងស្ទះសវនាការ។ ការមិនទទួល ជួនកាលដោយសារភាគីធ្វេសប្រហែស មិនបានសិក្សាហ្មត់ចត់ និងមិនដាក់ឯកសារទាន់ពេលវេលាកំណត់ (Gillian Higgins, Milosevic S. in Antonio Cassese, the Oxford Companion to the International Criminal Justice, 2009, pp. 811-815)។ ៤. សម្រាប់សេចក្តីសម្រេចស្រដៀងគ្នានឹងសេចក្តីសម្រេចសង្ខេបនេះ ក្នុងសំណុំរឿង ០០២ សូមមើល http://www.measboralaws.com/detail/1056។